ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តរតនគិរី

សាលក្រមព្រហ្មទណ្ឌ

-លេខៈ ០១ "ខ"

ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០២៣

-សំណុំរឿងព្រហ្មទណ្ឌលេខ ៧១

ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១៩

-សំណុំរឿងស៊ើបសួរលេខ ១២៧

ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០១៩

-សំណុំរឿងជំនុំជម្រះលេខ ៦៥៥

ចុះថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០២០

## នាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តរតនគិរី

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី២៦ ខែតុលា ឆ្នាំ២០២២ វេលាម៉ោង ០៨ និង ៣០ នាទីព្រឹក នៅសាលសវនាការជាន់លើ ដោយមានសមាសភាព ៖

**ចៅក្រមជំនុំជម្រះ**

-លោកចៅក្រម [redacted] ជាចៅក្រមជំនុំជម្រះសាលាដំបូងខេត្តរតនគិរី

**តំណាងអយ្យការ**

-លោក [redacted] ព្រះរាជអាជ្ញារងនៃអយ្យការអមសាលាដំបូងខេត្តរតនគិរី

**ក្រឡាបញ្ជីសវនាការ**

-លោក [redacted] ក្រឡាបញ្ជីនៃសាលាដំបូងខេត្តរតនគិរី

ដើម្បីជំនុំជម្រះលើបណ្តឹងទាស់ ក្នុងសំណុំរឿងព្រហ្មទណ្ឌលេខ ៧១ ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១៩ ដែលមានពិរុទ្ធជន ៖

-ឈ្មោះ [redacted] ភេទប្រុស អាយុ ៥៨ឆ្នាំ ជនជាតិខ្មែរ មុខរបរម្ចាស់អាជីវកម្មដឹកជញ្ជូនសម្រាមក្នុងក្រុងបានលុង មានទីកន្លែងកំណើតភូមិ [redacted] ខេត្តកណ្តាល និងទីលំនៅបច្ចុប្បន្ន [redacted] ខេត្តរតនគិរី ឪពុកឈ្មោះ [redacted] សុង "ស" ម្តាយឈ្មោះ [redacted] វួច "ស" មានប្រពន្ធឈ្មោះ [redacted] សុណា "រ" មានកូន ០២នាក់ ជានីតិជន, ប្រវត្តិនៃការផ្តន្ទាទោសពីមុន "គ្មាន" ។

-ដោយមានលោក [redacted] ជាមេធាវីការពារសិទ្ធ ។

ជាប់ចោទពីបទ **ការក្លែងបន្លំ និងប្រើប្រាស់ឯកសារសាធារណៈក្លែង** ប្រព្រឹត្តនៅចំណុចភូមិសាស្ត្រក្រុងបានលុង ខេត្តរតនគិរី កាលពីថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១៨ បទល្មើសដែលមានបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា ៦២៦, មាត្រា ៦២៧ និង មាត្រា ៦៣០ នៃក្រមព្រហ្មទណ្ឌ ។

**-ដើមបណ្តឹងរដ្ឋប្បវេណី** ឈ្មោះ [redacted] **ឆាយ** ភេទប្រុស អាយុ ៣២ឆ្នាំ ជនជាតិខ្មែរ មុខរបរមន្ត្រីបរិស្ថាន មានទីកន្លែងកំណើតភូមិគោកអំពៅ ឃុំស្រង៉ែ ស្រុកទ្រាំង ខេត្តតាកែវ ទីលំនៅបច្ចុប្បន្នភូមិអូរកន្ធៀង សង្កាត់បឹងកន្សែង ក្រុងបានលុង ខេត្តរតនគិរី ឪពុកឈ្មោះ [redacted] **ឡុង** (ស) ម្តាយឈ្មោះ [redacted] ហ៊ី (រ) ប្រពន្ធឈ្មោះ [redacted] ស្ទូលី (លែងលះ) មានកូនចំនួន ០១នាក់ ជានីតិជន។ **(អវត្តមាន)**

**-ដើមបណ្តឹងរដ្ឋប្បវេណី** ឈ្មោះ [redacted] ប៊ុនណា ភេទប្រុស អាយុ ៤៨ឆ្នាំ ជនជាតិខ្មែរ មុខរបរប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានទីកន្លែងកំណើតភូមិរកាកណ្តាល ឃុំរកាកណ្តាល ស្រុកក្រចេះ ខេត្តក្រចេះ ទីលំនៅបច្ចុប្បន្នភូមិជ័យជំនះ សង្កាត់ឡាបានសៀក ក្រុងបានលុង ខេត្តរតនគិរី ឪពុកឈ្មោះ [redacted] **អេង** (រ) ម្តាយឈ្មោះ [redacted] ផួង (រ) ប្រពន្ធឈ្មោះ [redacted] វ៉ូមី មានកូនចំនួន ០៣នាក់ ជានីតិជន ។ **(អវត្តមាន)**

**-ដើមបណ្តឹងរដ្ឋប្បវេណី** ឈ្មោះ [redacted] **គីមហ៊ាន** ភេទប្រុស អាយុ ៥៦ឆ្នាំ ជនជាតិខ្មែរ មុខរបរអនុប្រធានមន្ទីរសាធារណៈការ មានទីកន្លែងកំណើតភូមិ២ ឃុំត្រពាំងក្រហម ស្រុកលំផាត់ ខេត្តរតនគិរី ទីលំនៅបច្ចុប្បន្នភូមិអូរកន្ធៀង សង្កាត់បឹងកន្សែង ក្រុងបានលុង ខេត្តរតនគិរី ឪពុកឈ្មោះ [redacted] សារុន (ស) ម្តាយឈ្មោះ [redacted] ប៉ុន (ស) ប្រពន្ធឈ្មោះ [redacted] **ទិត្យចិន្តា** មានកូនចំនួន ០៤នាក់ ជានីតិជន ។ **(អវត្តមាន)**



Scanned with CamScanner

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ស៊ីណេត ភេទប្រុស អាយុ ៦០ឆ្នាំ ជនជាតិខ្មែរ មុខរបរប្រធានក្រុមប្រឹក្សាក្រុងបានលុង មានទីកន្លែងកំណើតភូមិគ្រាំងស្វាយ ឃុំព្រែកកំពឹស ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ទីលំនៅបច្ចុប្បន្នភូមិថ្មដា សង្កាត់បឹងកន្សែង ក្រុងបានលុង ខេត្តរតនគិរី ឪពុកឈ្មោះ [redacted] យឿន (ស) ម្តាយឈ្មោះ [redacted] យុង (រ) ប្រពន្ធឈ្មោះ [redacted] សាលីម មានកូនចំនួន ០៥នាក់ ជានីតិជន ។ **អវត្តមាន**

-ដោយមានលោក [redacted] ជាមេធាវីការពារសិទ្ធ ។

-សាក្សី ឈ្មោះ [redacted] ខេមរៈ ភេទប្រុស អាយុ ៣៩ឆ្នាំ ជនជាតិខ្មែរ មុខរបរមន្ត្រីរាជការ មានទីកន្លែងកំណើតភូមិថ្មលាត សង្កាត់ស្រះឬស្សី ក្រុងស្ទឹងត្រែង ខេត្តស្ទឹងត្រែង ទីលំនៅបច្ចុប្បន្នភូមិអូរកន្ធិល សង្កាត់បឹងកន្សែង ក្រុងបានលុង ខេត្តរតនគិរី ឪពុកឈ្មោះ [redacted] ចង សុំ (រ) ម្តាយឈ្មោះ [redacted] ប៊ុនឡៀ (រ) ប្រពន្ធឈ្មោះ [redacted] ស្រីមុំ មានកូនចំនួន ០២នាក់ ជានីតិជន ។

-សាក្សី ឈ្មោះ [redacted] ណាយ ភេទស្រី អាយុ ២៥ឆ្នាំ ជនជាតិខ្មែរ មុខរបរប្រជាពលរដ្ឋ មានទីកន្លែងកំណើតភូមិ៤ សង្កាត់ឡាបានសៀក ក្រុងបានលុង ខេត្តរតនគិរី ទីលំនៅបច្ចុប្បន្នភូមិអូរកន្ធិល សង្កាត់បឹងកន្សែង ក្រុងបានលុង ខេត្តរតនគិរី ឪពុកឈ្មោះ [redacted] ថាវី (រ) ម្តាយឈ្មោះ [redacted] ខាំឡៃ (រ) ប្តីឈ្មោះ [redacted] ពិសិទ្ធ មានកូនចំនួន ០១នាក់ ជានីតិជន ។ **អវត្តមាន**

-សាក្សី ឈ្មោះ [redacted] សោភា ភេទប្រុស អាយុ ៣៨ឆ្នាំ ជនជាតិខ្មែរ មុខរបរប្រធានមន្ទីរមុខងារសាធារណៈ មានទីកន្លែងកំណើតភូមិស្នារកោះ ឃុំកោះសាឡាយ ស្រុកសៀមបូក ខេត្តស្ទឹងត្រែង ទីលំនៅបច្ចុប្បន្នភូមិជ័យជំនះ សង្កាត់ឡាបានសៀក ក្រុងបានលុង ខេត្តរតនគិរី ឪពុកឈ្មោះ [redacted] វ៉េវ (ស) ម្តាយឈ្មោះ [redacted] សាវ៉ាន់ (ស) ប្រពន្ធឈ្មោះ [redacted] ប្រាថ្នា មានកូនចំនួន ០៣នាក់ ជានីតិជន ។ **អវត្តមាន**

-សាក្សី ឈ្មោះ [redacted] សំអាត ភេទប្រុស អាយុ ៤៧ឆ្នាំ ជនជាតិខ្មែរ មុខរបរមេភូមិ មានទីកន្លែងកំណើតភូមិសណ្តាត ឃុំអង្គកាស្ទ ស្រុកស្វាយជ្រំ ខេត្តស្វាយរៀង ទីលំនៅបច្ចុប្បន្នភូមិ៧មករា សង្កាត់ឡាបានសៀក ក្រុងបានលុង ខេត្តរតនគិរី ឪពុកឈ្មោះ [redacted] ចន (ស) ម្តាយឈ្មោះ [redacted] យ៉ារី (រ) ប្រពន្ធឈ្មោះ [redacted] សុផាត ជានីតិជន ។ **អវត្តមាន**

## អង្គហេតុនៃរឿងមានដូចតទៅ

កាលពីថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១៨ វេលាម៉ោង ០៩ និង០០នាទី មានករណី **ការក្លែងបន្លំ និងប្រើប្រាស់ឯកសារសាធារណៈក្លែង** ស្ថិតក្នុងភូមិសាស្ត្រក្រុងបានលុង ខេត្តរតនគិរី កើតឡើងដោយជនសង្ស័យឈ្មោះ [redacted] គួង បានក្លែងបន្លំឯកសារ និងប្រើប្រាស់ឯកសារសាធារណៈក្លែង សៀវភៅបន្ទុកភាស៊ី ស្តីពីការដាក់ទុនវិនិយោគ និងធ្វើអាជីវកម្មប្រមូលសម្អាតអនាម័យ និងដឹកជញ្ជូនសំរាមក្នុងក្រុងបានលុង ខេត្តរតនគិរី កិច្ចសន្យាស្តីពីការដាក់ទុនវិនិយោគ និងធ្វើអាជីវកម្មប្រមូល សម្អាត និងដឹកសំរាមក្នុងក្រុងបានលុង ខេត្តរតនគិរី ដែលខុសពីឯកសារដើមដែលក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានចេញឱ្យប្រើ និងតម្កល់ទុកនៅមន្ទីរដែលពាក់ព័ន្ធក្នុងខេត្តរតនគិរី ។

-បានឃើញ សាលក្រមព្រហ្មទណ្ឌលេខ **២២០ "ច" ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២២** របស់សាលាដំបូងខេត្តរតនគិរី ។

-បានឃើញ លិខិតជូនដំណឹងសាលក្រមកំបាំងមុខលេខ ៥៧៧ "ច" ព្រ.ទ ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០២២ របស់ក្រឡាបញ្ជី នៃសាលាដំបូងខេត្តរតនគិរី ។

-បានឃើញ ពាក្យបណ្តឹងទាស់ ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២២ របស់ពិរុទ្ធជនឈ្មោះ [redacted] គួង ។

-បានឃើញ សេចក្តីចម្លងបណ្តឹងទាស់ ចុះថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២២ របស់សាលាដំបូងខេត្តរតនគិរី ។

## នាពេលសវនាការ

-ពិរុទ្ធជនឈ្មោះ [redacted] គួង នាពេលសវនាការបានឆ្លើយថា៖ ខ្លួនសូមរក្សាចម្លើយដែលឆ្លើយនៅដំណាក់កាលអយ្យការទុកនៅដែល នៅក្នុងខេត្តរតនគិរីមានការស្មុគស្មាញពាក់ព័ន្ធនឹងសំរាម ដោយគ្មានអ្នកប្រមូលនោះទេ ប៉ុន្តែដោយខាងសាលាខេត្តត្រូវការអ្នកវិនិយោគ ខ្លួនក៏បានចូលវិនិយោគសំរាមនេះតែម្តង ដោយពីមុនឡើយគឺខាងសាលាក្រុងជាអ្នកប្រមូលសំរាម ខ្លួនក៏បានដាក់ពាក្យសុំចូលតាមបែបបទរដ្ឋបាល ហើយខាងអភិបាលខេត្តរតនគិរីបានចេញលិខិតលេខ

១៤១/០៨ ល.អ.ខ ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០០៨ ស្តីពីការប្រគល់សិទ្ធិអនុញ្ញាតឲ្យធ្វើអាជីវកម្មប្រមូលសម្អាត និងដឹកជញ្ជូនសំរាមជាបណ្តោះអាសន្នរយៈពេល ០៣ខែ គឺចាប់ពីខែតុលា ដល់ខែធ្នូ ឆ្នាំ២០០៨ ដែលមានឈ្មោះខ្លួនជាម្ចាស់អាជីវកម្ម ដោយយោងលើកំណត់ហេតុរបស់សាលាខេត្តរតនគិរី ចុះថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០០៨ និងពាក្យស្នើសុំធ្វើអាជីវកម្មប្រមូលសម្អាត និងដឹកជញ្ជូនសំរាមក្រុងបានលុង ចុះថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០០៨ ក្រោយពីអនុវត្តក្នុងអំឡុងពេល ០៣ខែនោះគឺឃើញថាប្រជាពលរដ្ឋខ្លះចូលរួមសហការ និងខ្លះទៀតមិនព្រមសហការក្នុងកាតព្វកិច្ចបង់ប្រាក់អនាម័យ បន្ទាប់ពីចេញលិខិតបណ្តោះអាសន្នរួចហើយ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានចេញលិខិតលេខ ៦៩២ ស.ហ.វ ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០១០ ដោយលិខិតនោះគឺមានខ្លឹមសារឲ្យខ្លួនបានបំពេញកាតព្វកិច្ចតាមមុខសញ្ញាដែលមានចែងក្នុងសៀវភៅបន្ទុក ។ ក្រោយមកទៀតខាងសាលាក្រុងបានប្រគល់រថយន្តដឹងសម្រាមមកឲ្យខ្លួន ដែលមានលិខិតលេខ ២៤៥/០៨ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៨ ក្នុងការជួសជុលរថយន្ត លោក[redacted] វិន បានឲ្យខ្លួនចេញថ្លៃជួសជុលចំនួន ៤២០០ ដុល្លារ ហើយគាត់បានចុះចូលក្នុងកិច្ចសន្យាជាមួយខ្លួនឲ្យបង់រំលោះរថយន្តនោះជាមួយរដ្ឋក្នុងតម្លៃ ៥០០០ ដុល្លារ ប៉ុន្តែខ្លួនមិនព្រមនោះទេ ដោយសារគាត់យកថ្លៃជួសជុល ។ ពាក់ព័ន្ធនិងសៀវភៅបន្ទុកដែលខ្លួនចុះហត្ថលេខានៅថ្ងៃដែលខាងសាលាក្រុងបានចុះទៅសាកសួរ ដែលមានលោក[redacted] ស៊ីផេត បានយកសៀវភៅបន្ទុក និងកិច្ចសន្យាខាងលើនោះជាសៀវភៅបន្ទុកដែលខ្លួនយកមកអនុវត្តប្រចាំថ្ងៃពិតប្រាកដមែន ព្រោះទី១ សផវភៅបន្ទុកភាស៊ី ស្តីពីការដាក់ទុនវិនិយោគ និងធ្វើអាជីវកម្ម ប្រមូលសម្អាត អនាម័យ និងដឹកជញ្ជូនសម្រាម ក្នុងក្រុងបានលុង ខេត្តរតនគិរី និងទី២ កិច្ចសន្យាដាក់ទុនវិនិយោគ និងធ្វើអាជីវកម្មប្រមូល សម្អាត និងដឹកសម្រាមក្នុងក្រុងបានលុង ខេត្តរតនគិរី ។ ចាប់តាំងពីអនុវត្តសៀវភៅបន្ទុកនៅថ្ងៃទី០១ ខែមករា ឆ្នាំ២០១០ ដោយមានចុះហត្ថលេខាមន្ទីរហិរញ្ញវត្ថុ និងអភិបាលខេត្តរតនគិរី គឺមានរយៈពេល ០៩ឆ្នាំមកហើយ ។ ចំពោះសៀវភៅបន្ទុក និងកិច្ចសន្យា ដែលតម្កល់ទាំង ០៩ស្ថាប័ន និងសៀវភៅបន្ទុក និងកិច្ចសន្យារបស់ខ្លួនមានការខុសគ្នាទាំងស្រុង ទាំងខ្លឹមសារ ក៏ដូចជាតម្លៃ ខ្លួនមិនដឹងនោះទេ ដោយខ្លួនគ្រាន់តែដឹងថាសៀវភៅបន្ទុក និងកិច្ចសន្យាដែលគណៈកម្មការខេត្តប្រគល់មកឲ្យខ្លួនអនុវត្តនោះគឺខ្លួនមិនអនុវត្តតាមសៀវភៅ និងកិច្ចសន្យាដែលកន្លងមកលោក[redacted] សោភា ជាអ្នកអង្គុយធ្វើសៀវភៅបន្ទុក និងកិច្ចសន្យាដែលមានខ្លឹមសារដដែល ដែលធ្វើជាមួយខ្លួនពេលកន្លងមក ។ ហើយសៀវភៅបន្ទុក និងកិច្ចសន្យាដែលខ្លួនប្រើនោះគឺបានមកពីមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្តរតនគិរី ប៉ុន្តែខ្លួនមិនចាំថាអ្នកណាជាអ្នកប្រគល់ឲ្យខ្លួននោះទេ ហើយខ្លួនក៏មិនបានដឹងថាសៀវភៅបន្ទុក និងកិច្ចសន្យាដែលខ្លួនប្រើរយៈពេល ០៩ឆ្នាំនេះជាសៀវភៅ និងកិច្ចសន្យាក្លែងក្លាយដែរ ។ ពាក់ព័ន្ធប័ណ្ណប្រមូលលុយសម្រាមគឺខ្លួនពិតប្រាកដមែន គឺដោយសារមានការអនុញ្ញាតពីប្រធានមន្ទីរសេដ្ឋកិច្ច ហិរញ្ញវត្ថុខេត្តរតនគិរី ដោយបានជជែកគ្នាក្នុងអង្គប្រជុំដោយលក់វិក័យប័ត្រក្នុងមួយក្បាល ៧០០០ រៀល ហើយមានតែ ១០០សន្លឹក ទើបឈ្មោះ[redacted] សុថារ័ត្ន ជាអ្នកអនុញ្ញាតដោយខ្លួនឯងតែម្តង ដោយក្នុង ១០០០សន្លឹកអស់តែចំនួន ៣០០០រៀល នោះទេ ។ ហើយខាងមន្ទីរសេដ្ឋកិច្ច ហិរញ្ញវត្ថុខេត្តរតនគិរី មិនអាចចងប្រព័ន្ធលើវិក័យប័ត្រក្នុងការប្រមូលលុយតាមផ្ទះ ឲ្យខ្លួនបានទើបលោក[redacted]សុថារ័ត្ន បានសម្រេចឲ្យខ្លួនធ្វើដោយខ្លួនឯងទៅ ។ សូមលោកតំណាងអយ្យការមេត្តាកោះហៅសាក្សី [redacted] វីដា ឈ្មោះ [redacted] សុថារ័ត្ន ។ លោកតំណាងអយ្យការមេត្តាជួយរកយុត្តិធម៌ឲ្យរូបខ្លួនច្រានចោលពាក្យបណ្តឹងចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១៨ ,ចហរានចោលការសន្និដ្ឋានរបស់សមត្ថកិច្ច សូមតម្កល់រឿងនេះទុកឥតចាត់ការ ។ ព្រោះកូនក្តីរបស់ខ្លួនមិនបានប្រព្រឹត្តដូចកាតចោទប្រកាន់របស់សហដើមបណ្តឹង និងសមត្ថកិច្ច ។

ដូចខាងក្រោមមានពីចំណុចទី ០១ ដល់ចំណុចទី ០៥ ក្រោយពីក្រសួងសេដ្ឋកិច្ចហិរញ្ញវត្ថុបានចេញលិខិតរួចរាល់ហើយ គឺខាងក្រសួងបានឲ្យសាលាខេត្តរតនគិរី រៀបចំឯកសារជាកិច្ចសន្យា និងសៀវភៅបន្ទុកភាស៊ី បន្ទាប់មកប្រធានមន្ទីរហិរញ្ញវត្ថុខេត្តរតនគិរី បានធ្វើកំណត់បង្ហាញរឿងដោយយោងតាមលិខិតលេខ ៦៩២ ស.ហ.វ ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០១០ ដើម្បីឲ្យមានការចូលរួម ទី១ លោក [redacted]វីដា ជាប្រធានការិយាល័យទ្រព្យសម្បត្តិរដ្ឋ ទី២ អនុប្រធានសេដ្ឋកិច្ចមន្ទីរហិរញ្ញវត្ថុខេត្តរតនគិរី លោក[redacted]សោភា ទី៣ ប្រធានមន្ទីសេដ្ឋកិច្ចហិរញ្ញវត្ថុខេត្តរតនគិរី លោក[redacted]សុថារ័ត្ន ទី៤ ឯកឧត្តម [redacted] សារឿន ជាអភិបាលរងខេត្តទទួលបន្ទុកវេញថ្លៃភាស៊ីខេត្តរតនគិរី ទី៥ ហត្ថលេខាឯកភាពពីឯកឧត្តម [redacted] ហាមផាន បន្ទាប់មកទៀតលោក [redacted]សោភា បានរៀបចំកិច្ចសន្យាស្តីពីការដាក់ទុនវិនិយោគ ធ្វើអាជីវកម្មប្រមូលសម្រាមក្នុងក្រុងបានលុង ខេត្តរតនគិរី ចុះថ្ងៃទី០១ ខែមករា ឆ្នាំ២០១០ ចំពោះឯកសារនេះទៀតសោត គឺខាងមន្ទីរហិរញ្ញវត្ថុបានប្រគល់

ឱ្យមកខ្លួនយកមកត្រួតពិនិត្យសិនថា តើខ្លួនឯកភាពលើកិច្ចសន្យានេះដែលឬអត់ បន្ទាប់ពីបានមើលរួចហើយ ខ្លួនបានសំណូមពរឱ្យលោកប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឱ្យកែចំណុចខ្លះក្នុងកិច្ចសន្យា ហើយលោក[redacted]សុផារ័ត្ន និងលោក [redacted] សោភា បានឯកភាពកែក្នុងកិច្ចសន្យាក្នុងចំណុចខ្លះ ក្រោយពីឯកភាពក្នុងកិច្ចសន្យាដែលបានកែរួចហើយ គឺលោក [redacted] សោភា បានរៀបចំសៀវភៅបន្ទុកភាស៊ី ស្តីពីការដាក់ទុនវិនិយោគធ្វើអាជីវកម្មប្រមូលសម្អាត អនាម័យ និងដឹកជញ្ជូនសម្រាមក្នុងក្រុងបានលុង ខេត្តរតនគិរី ឱ្យធ្វើអាជីវកម្មប្រមូលភាស៊ីរយៈពេល ២១ឆ្នាំ ចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០១០ ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០៣០ សៀវភៅបន្ទុកនេះគឺមានការតវ៉ាគ្នា ដើម្បីចុះក្នុងសៀវភៅបន្ទុក និងយកមកអនុវត្តតែម្តង ពេលនោះគឺខ្លួនបានឈប់ប្រើលិខិតបណ្តោះអាសន្នហើយ ខ្លួនបែរមកប្រើសៀវភៅបន្ទុកដែលមានចុះហត្ថលេខាពីមន្ទីរហិរញ្ញវត្ថុ និងអភិបាលខេត្តរតនគិរី នៅពេលដែលអនុវត្តសៀវភៅបន្ទុកនេះ គឺឃើញថាប្រជាពលរដ្ឋខ្លះនៅតែមិនចូលរួមបង់លុយតាមសៀវភៅបន្ទុកនេះដែរ ហើយខ្លួននៅតែបន្តក្នុងការប្រឹងប្រែងអនុវត្តតាមសៀវភៅបន្ទុក លុះមកដល់បន្តទៀតសៀវភៅបន្ទុកដែលខ្លួនយកមកអនុវត្តនោះ បានរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចហិរញ្ញវត្ថុ បានចូលរួមចុះហត្ថលេខាទទួលស្គាល់សៀវភៅបន្ទុករបស់ខ្លួនតាមផ្លូវច្បាប់ ហើយខ្លួនក៏បានចាប់ផ្តើមអនុវត្តតាមសៀវភៅបន្ទុកចាប់តាំងពីថ្ងៃនោះមក ប៉ុន្តែប្រជាពលរដ្ឋខ្លះនៅតែមិនបានបង់ថ្លៃតាមសៀវភៅ បន្ទុកដែរ ក្រោយមកទៀតដោយមានការខ្វះខាតលើចំណុចអាជីវកម្មក្នុងការប្រមូលភាស៊ីអនាម័យ ខ្លួនក៏បានស្នើសុំឧបសម្ព័ន្ធចុះថ្ងៃទី២១ ខែសីហា ឆ្នាំ២០១០ ក្រោមអធិបតីភាពឯកឧត្តម [redacted] សារឿន អភិបាលរងខេត្តរតនគិរី ជាប្រធានអង្គប្រជុំ កំណត់ហេតុស្តីពីការពិភាក្សាស្តីពីការធ្វើឧបសម្ព័ន្ធថ្លៃឈ្នួលសេវាដឹកសម្រាមបន្ថែមលើតារាងថ្លៃឈ្នួល ដែលមានចែងក្នុងសៀវភៅបន្ទុក ក្រោយមកទៀតខាងសាលាក្រុង ប្រគល់រថយន្តដឹកសម្រាមមកឱ្យខ្លួនដែលមានលិខិត **២៤៥/០៩ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៩** ក្នុងការជួសជុលរថយន្តលោក[redacted]**វិន** បានឱ្យខ្លួនចេញថ្លៃជួសជុលចំនួន ៤២០០ (**បួនពាន់**) ដុល្លារអាមេរិក ហើយគាត់បានចុះក្នុងកិច្ចសន្យាជាមួយខ្លួនឱ្យបង់រំលស់រថយន្តនោះជាមួយរដ្ឋក្នុងតម្លៃ ៥០០០ (ប្រាំពាន់) ដុល្លារអាមេរិក ប៉ុន្តែខ្លួនមិនព្រមនោះទេ ដោយសារគាត់យកថ្លៃជួសជុល ពាក់ព័ន្ធសៀវភៅបន្ទុកដែលខ្លួនចុះហត្ថលេខា នៅថ្ងៃដែលខាងសាលាក្រុងបានចុះទៅសាកសួរដែលមានលោក [redacted] ស៊ីដេត បានយកសៀវភៅបន្ទុក និងកិច្ចសន្យាខាងលើនោះ ជាសៀវភៅបន្ទុកដែលខ្លួនយកមកអនុវត្តប្រចាំថ្ងៃពិតប្រាកដមែន ព្រោះទី១ សៀវភៅបន្ទុកភាស៊ីស្តីពីការដាក់ទុនវិនិយោគ និងធ្វើអាជីវកម្មប្រមូលសម្អាត អនាម័យ និងដឹកជញ្ជូនសំរាមក្នុងក្រុងបានលុង ខេត្តរតនគិរី និងទី២ កិច្ចសន្យាដាក់ទុនវិនិយោគ និងធ្វើអាជីវកម្មប្រមូលសំអាត អនាម័យ និងដឹកជញ្ជូនសម្រាមក្នុងក្រុងបានលុង ខេត្តរតនគិរី ចាប់តាំងពីអនុវត្តសៀវភៅបន្ទុកនៅថ្ងៃទី០១ ខែមករា ឆ្នាំ២០១០ ដោយមានហត្ថលេខាមន្ទីរហិរញ្ញវត្ថុ និងអភិបាលរងខេត្តរតនគិរី គឺមានរយៈពេល ០៩ឆ្នាំ មកហើយ ចំពោះសៀវភៅបន្ទុក និងកិច្ចសន្យាដែលតម្កល់ទាំង ០៩ស្ថាប័ន សៀវភៅបន្ទុក និងកិច្ចសន្យារបស់ខ្លួនមានការខុសគ្នាទាំងស្រុង ទាំងខ្លឹមសារ ក៏ដូចជាតម្លៃខ្លួនមិនដឹងនោះទេ ដោយគ្រាន់តែដឹងថាសៀវភៅបន្ទុក និងកិច្ចសន្យាដែល គណៈកម្មការខេត្តប្រគល់ឱ្យខ្លួនអនុវត្តនោះ គឺខ្លួនអនុវត្តតាមសៀវភៅ និងកិច្ចសន្យាដែលកន្លងមកលោក [redacted] សោភា ជាអ្នកអង្គុយធ្វើសៀវភៅបន្ទុក និងកិច្ចសន្យាដែលមានអត្ថន័យខ្លឹមសារដដែល ដែលធ្វើជាមួយខ្លួនកន្លងមក ហើយសៀវភៅបន្ទុក និងកិច្ចសន្យាដែលខ្លួនប្រើនោះ គឺខ្លួនបានពីមន្ទីរសេដ្ឋកិច្ចហិរញ្ញវត្ថុខេត្តរតនគិរី ប៉ុន្តែខ្លួនមិនចាំថានរណាជាអ្នកប្រគល់ឱ្យខ្លួននោះទេ ហើយខ្លួនមិនដឹងថាសៀវភៅបន្ទុក និងកិច្ចសន្យាដែលខ្លួនប្រើរយៈពេល ០៩ឆ្នាំ នេះជាសៀវភៅ និងកិច្ចសន្យាក្លែងក្លាយដែរ ពាក់ព័ន្ធប័ណ្ណប្រមូលលុយសម្រាម គឺខ្លួនពិតជាបានធ្វើដោយខ្លួនឯងពិតប្រាកដមែន គឺដោយសារមានការអនុញ្ញាតពីប្រធានមន្ទីរហិរញ្ញវត្ថុខេត្តរតនគិរី ដោយបានជជែកគ្នាក្នុងអង្គប្រជុំដោយលក់វិក័យប័ត្រក្នុងមួយក្បាល ៧០០០ (ប្រាំពីរពាន់) រៀល ហើយមានតែ ១០០ (មួយរយ) សន្លឹក ទើបឈ្មោះ[redacted] សុផារ័ត្ន ជាអ្នកអនុញ្ញាតឱ្យខ្លួនឯងតែម្តង ដោយក្នុង ១០០០ (មួយពាន់) សន្លឹក អស់តែចំនួន ៣០០០ (បីពាន់) រៀល នោះទេ ហើយខាងមន្ទីរសេដ្ឋកិច្ចហិរញ្ញវត្ថុខេត្តរតនគិរី មិនអាចចងប្រព័ន្ធលើវិក័យប័ត្រ ការប្រមូលសម្រាមតាមផ្ទះឱ្យខ្លួនបានទើបលោក [redacted]សុផារ័ត្ន បានសម្រេចឱ្យខ្លួនធ្វើដោយខ្លួនឯងទៅ ។

-ក្រឡាបញ្ជីបានអានចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ[redacted]ប៊ុនណា, ឈ្មោះ[redacted]គឹមហ៊ាន, ឈ្មោះ[redacted]ស៊ីដេត , ឈ្មោះ [redacted] គាយ បានឆ្លើយនៅដំណាក់កាលអយ្យការ និងដំណាក់កាលចៅក្រមស៊ើបសួរ ប្រហាក់ប្រហែលគ្នាថា: ចំពោះសៀវភៅបន្ទុកភាស៊ីស្តីពីការដាក់ទុនវិនិយោគ និងធ្វើអាជីវកម្មប្រមូលសម្អាត អនាម័យ និងដឹកជញ្ជូនសំរាមក្នុងក្រុង



Scanned with CamScanner

បានលុង ខេត្តរតនគិរី ដែលឈ្មោះ [redacted] គួង យកមកប្រើប្រាស់ជាមួយប្រជាជនក្រុងបានលុង ជាសៀវភៅបន្ទុកក្លែងក្លាយ ព្រោះសៀវភៅក្លែងនេះ គឺមានការមិនប្រក្រតីត្រង់ចំណុចចាប់ពីជំពូកទី១ ប្រការ៥ និងខ្លឹមសារទាំងស្រុងក្នុងសៀវភៅបន្ទុកនេះ ព្រោះសៀវភៅបន្ទុកក្លែងគឺមានលក្ខណៈខុសទាំងខ្លឹមសារ ចំនួនលុយយកភាស៊ីទម្រង់អក្សរគឺខុសពីសៀវភៅបន្ទុកដើមដែលខាងក្រសួងចេញឱ្យ គឺខុសពីសៀវភៅទាំង ០៩ស្ថាប័នដែលបានតម្កល់ទុកទាំងស្រុងតែម្តង ហើយឈ្មោះ [redacted] គួង បានបោះពុម្ពបង្កាន់ដៃយកភាស៊ីដោយខ្លួនឯងថែមទៀតផង ព្រោះបង្កាន់ដៃប្រមូលភាស៊ីខាងមន្ទីរជាអ្នកចេញឱ្យ ប៉ុន្តែបែរជាឈ្មោះ [redacted] គួង លួចបោះពុម្ពដោយមិនបានឆ្លងកាត់មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុទៅវិញ ចំពោះភស្តុតាងខ្លួនបានដាក់ជូនទៅស្នងការនគរបាលខេត្តរតនគិរីរួចរាល់ហើយ សូមលោកតំណាងអយ្យការមេត្តាជួយចោទប្រកាន់ និងផ្តន្ទាទោសឈ្មោះ [redacted] គួង តាមផ្លូវច្បាប់ ។

-សាក្សីឈ្មោះ [redacted] ខេមរៈ នាពេលសវនាការបានឆ្លើយថាៈ ខ្លួននៅរក្សាចម្លើយដែលបានឆ្លើយនៅដំណាក់កាលអយ្យការដដែល កាលពីអំឡុងឆ្នាំ២០១៧ ក្រុមការងារគណៈកម្មការត្រួតពិនិត្យ និងវាយតម្លៃក្រុមហ៊ុនប្រមូល និងដឹកជញ្ជូនសំរាម [redacted] ជ្រា ដែលមានឈ្មោះ [redacted] គួង ជាប្រធានក្រុមហ៊ុន នៅពេលដែលគណៈកម្មការចុះទៅពិនិត្យកន្លែងចាក់សំរាម គឺឃើញថាមានការចាក់សំរាម មិនត្រឹមត្រូវតាមលក្ខណៈបច្ចេកទេសនោះទេ ចំណែកគណៈកម្មការបានត្រួតពិនិត្យតាមដងផ្លូវ និងសង្កាត់ឃើញថាការបំពាក់ធុងសំរាមមិនគ្រប់តាមកិច្ចសន្យា ចំពោះសៀវភៅបន្ទុកភាស៊ីស្តីពីការដាក់ធុងវិនិយោគ និងធ្វើអាជីវកម្មប្រមូលសម្អាត អនាម័យ និងដឹកជញ្ជូនសំរាមក្នុងក្រុងបានលុងដែលឈ្មោះ [redacted] គួង យកមកប្រើប្រាស់ជាសៀវភៅបន្ទុកក្លែងក្លាយ គឺមានការមិនប្រក្រតីត្រង់ចំណុចចាប់ពីជំពូកទី១ ប្រការ៥ និងខ្លឹមសារទាំងស្រុងក្នុងសៀវភៅនេះ សៀវភៅបន្ទុកក្លែង គឺមានលក្ខណៈខុសទាំងខ្លឹមសារ ចំនួនលុយយកភាស៊ី ទម្រង់អក្សរខុសពីសៀវភៅបន្ទុកដើមដែលខាងក្រសួងចេញឱ្យ គឺខុសពីសៀវភៅទាំង ០៩ស្ថាប័ន ដែលបានតម្កល់ទុកទាំងស្រុងតែម្តង នៅពេលក្រុមការងារចុះទៅដល់កន្លែងស្នាក់ការឈ្មោះ [redacted] គួង នោះគឺឈ្មោះនេះបានយកសៀវភៅបន្ទុកក្លែងប្រគល់ឱ្យគណៈកម្មការ ហើយឈ្មោះនេះបានបញ្ជាក់ថា សៀវភៅបន្ទុកក្លែងនេះគឺក្រុមហ៊ុន [redacted] ជ្រា បានយកមកអនុវត្តជាក់ស្តែង ហើយក្រុមការងារបានឱ្យឈ្មោះ [redacted] គួង ចុះហត្ថលេខាលើសៀវភៅបន្ទុកក្លែងក្លាយ ដែលគាត់យកមកអនុវត្តជាមួយប្រជាជនក្រុងបានលុងប្រចាំថ្ងៃ ហើយក្រុមការងារបានថតរូបពេលដែលឈ្មោះ [redacted] គួង ប្រគល់សៀវភៅបន្ទុកមកឱ្យក្រុមការងារទុកជាភស្តុតាង មិនតែប៉ុណ្ណោះក្រុមហ៊ុន [redacted] ជ្រា បានបោះពុម្ពវិក័យប័ត្របង់ប្រាក់ដោយខ្លួនឯង និងមានការប្រើប្រាស់ស្លាកនិមិត្តសញ្ញារបស់ក្រសួងថែមទៀតផង ខ្លួនសូមបញ្ជូលភស្តុតាងជា (Flash) ផ្ទុកវីដេអូ និងរូបថត ។

-ក្រឡាបញ្ជីបានអានចម្លើយរបស់សាក្សីឈ្មោះ [redacted]ណាយ បានឆ្លើយនៅដំណាក់កាលអយ្យការ និងដំណាក់កាលចៅក្រមស៊ើបសួរថាៈ ខ្លួនជាប្រជាពលរដ្ឋរស់នៅក្នុងភូមិ៧មករា ហើយកន្លងមករវាងខ្លួន និងលោក [redacted] គួង ពុំដែលមានទំនាស់អ្វីជាមួយគ្នានោះទេ ដោយឡែកកន្លងមកក្រុមហ៊ុន [redacted] ជ្រា គឺបានយកថ្លៃភាស៊ីសំរាម ២០០០០ (ពីរម៉ឺន) រៀល ក្នុងមួយខែហើយកន្លងមករូបខ្លួនពុំបានដឹងថាសៀវភៅក្នុងបន្ទុកគេយកភាស៊ីប៉ុន្មានទេ ទើបតែមានបញ្ហាធំទៅបានខ្លួនដឹងថាសៀវភៅក្នុងបន្ទុកភាស៊ីត្រឹមតែ ១០០០០ (មួយម៉ឺន) រៀលទេ កន្លងមកបើសិនជាខ្លួនដឹងថាក្រុមហ៊ុនគឺយកភាស៊ីខុសពីសៀវភៅបន្ទុក ខ្លួនតវ៉ាជាមិនខាន ហើយសព្វថ្ងៃនេះសាលាក្រុងបានយកភាស៊ីសំរាមចំនួន ១០០០០ (មួយម៉ឺន) រៀលក្នុងមួយខែ ហើយចំនួនក្នុងប័ណ្ណអនាម័យ និងដឹកជញ្ជូនសំរាមទាំងអស់របស់ក្រុមហ៊ុនដែលខ្លួនបានបង់ប្រាក់កន្លងមកគឺប័ណ្ណក្លែងក្លាយ ពីព្រោះអត់ការប្រថាប់ត្រាត្រឹមត្រូវ ។

-ក្រឡាបញ្ជីបានអានចម្លើយរបស់សាក្សីឈ្មោះ [redacted] សោភា បានឆ្លើយនៅដំណាក់កាលអយ្យការ និងដំណាក់កាលចៅក្រមស៊ើបសួរថាៈ រាល់ឯកសារសៀវភៅបន្ទុក និងកិច្ចសន្យារបស់ក្រុមហ៊ុនវិនិយោគ [redacted] ជ្រា ដែលមានឈ្មោះ [redacted] គួង ជាប្រធានក្រុមហ៊ុនបានស្នើសុំឱ្យប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុត្រួតពិនិត្យមើល និងបញ្ជូនទៅលោកប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុចុះហត្ថលេខា ហើយបញ្ជូនបន្តទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដើម្បីពិនិត្យ និងសម្រេចចុងក្រោយ ។ ក្រោយពីក្រសួងសេដ្ឋកិច្ចហិរញ្ញវត្ថុពិនិត្យ និងបានប្រថាប់ត្រារួចរាល់ហើយ ទើបខាងក្រសួងបញ្ជូនសៀវភៅ និងកិច្ចសន្យាមកឱ្យមន្ទីរហិរញ្ញវត្ថុដើម្បីអនុវត្ត ហើយច្បាប់ដើមមានចំនួន ១០ច្បាប់ មានប្រថាប់ត្រាក្រហមប្រគល់ឱ្យអ្នក

វិនិយោគឈ្មោះ [redacted] ត្លូង ០១ច្បាប់ និងស្ថាប័នពាក់ព័ន្ធចំនួន ០៩ច្បាប់ ដើម្បីតម្កល់ទុក ចំពោះខ្លឹមសារក្នុងសៀវភៅបន្ទុក និងកិច្ចសន្យាខាងក្រសួងមានការកែប្រែមួយចំនួន ហើយខាងមន្ទីរក៏បានជូនដំណឹងទៅឈ្មោះ [redacted] ត្លូង ហើយដែរ ដើម្បីយកទៅអនុវត្តដែលក្រសួងបានសម្រេចចុងក្រោយ ចំពោះសៀវភៅបន្ទុក និងកិច្ចសន្យាដែលឈ្មោះ [redacted] ត្លូង យកមកអនុវត្តប្រចាំថ្ងៃ គឺជាសៀវភៅ និងកិច្ចសន្យាក្លែងក្លាយ ព្រោះសៀវភៅបន្ទុកនេះមានការខុសគ្នាខ្លឹមសារមួយចំនួនពីសៀវភៅបន្ទុក និងកិច្ចសន្យាដែលក្រសួងប្រគល់ទៅឱ្យឈ្មោះ [redacted] ត្លូង និងតម្កល់ទុកនៅមន្ទីរពាក់ព័ន្ធទាំង ០៩ស្ថាប័ន ជាពិសេសខុសត្រង់តារាងតម្លៃឈ្នួលបង់ថ្លៃដឹកសម្រាមតែម្តង ចំពោះការអះអាងរបស់ឈ្មោះ [redacted] ត្លូង ថាខ្លួនបានពិភាក្សាតទល់គ្នារឿងតម្លៃជាមួយលោក [redacted] ត្លូង ដើម្បីចុះក្នុងសៀវភៅបន្ទុក និងកិច្ចសន្យាយកមកអនុវត្តតែម្តងនោះ គឺខ្លួនសុំបដិសេធចោល ព្រោះច្បាប់វិនិយោគភាសុី គឺគេយកការសម្រេចចុងក្រោយដែលមានហត្ថលេខា និងត្រារបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុយកមកអនុវត្ត ។

-ក្រឡាបញ្ជីបានអានចម្លើយរបស់សាក្សីឈ្មោះ [redacted] សំអាត ដែលបានឆ្លើយនៅដំណាក់កាលជំនុំជម្រះកំបាំងមុខជនជាប់ចោទថា: ខ្លួនជាមេភូមិ៧មករា ហើយកន្លងមករវាងខ្លួន និងលោក [redacted] ត្លូង ពុំដែលមានទំនាស់អ្វីជាមួយគ្នានោះទេ ដោយឡែកកន្លងមកក្រុមហ៊ុន [redacted] ជ្រា គឺបានយកថ្លៃភាសុីសំរាម ២០០០០ (ពីរម៉ឺន) រៀល ក្នុងមួយខែហើយកន្លងមករូបខ្លួនពុំបានដឹងថាសៀវភៅក្នុងបន្ទុកគេយកភាសុីប៉ុន្មានទេ ទើបតែមានបញ្ហាធំទៅបានខ្លួនដឹងថា សៀវភៅក្នុងបន្ទុកភាសុីត្រឹមតែ ១០០០០ (មួយម៉ឺន) រៀល ទេ កន្លងមកបើសិនជាខ្លួនដឹងថាក្រុមហ៊ុនគឺយកភាសុីខុសពីសៀវភៅបន្ទុកខ្លួនតវ៉ាជាមិនខាន ហើយសព្វថ្ងៃនេះសាលាក្រុងបានយកភាសុីសំរាមចំនួន ១០០០០ (មួយម៉ឺន) រៀល ក្នុងមួយខែ ហើយចំនួនក្នុងប័ណ្ណអនាម័យ និងដឹកជញ្ជូនសំរាមទាំងអស់របស់ក្រុមហ៊ុនដែលខ្លួនបានបង់ប្រាក់កន្លងមកគឺប័ណ្ណក្លែងក្លាយ ពីព្រោះអត់មានប្រថាប់ត្រាត្រឹមត្រូវ ។

## សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា: ក្រោយពីបានពិភាក្សាដេញដោលចប់ ឃើញថាតំណាងអយ្យការប្តឹងសុំឱ្យដើមបណ្តឹងទាំងអស់ដាក់ឯកសារដើមលើភស្តុតាងនានាដែលពាក់ព័ន្ធក្នុងសំណុំរឿង តែមកដល់ពេលនេះមិនទាន់បានដាក់មកតុលាការនោះទេ ដូច្នេះតំណាងអយ្យការប្តឹងសុំតុលាការពិចារណាឱ្យបានត្រឹមត្រូវតាមផ្លូវច្បាប់ ។

-ក្រោយពីបានស្តាប់ចម្លើយរបស់ពិរុទ្ធជន

-ក្រោយពីបានស្តាប់អំណានចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី

-ក្រោយពីបានស្តាប់អំណានចម្លើយរបស់សាក្សី

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានស្នើសុំរបស់មេធាវីការពារឱ្យដើមបណ្តឹងរដ្ឋប្បវេណី

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានស្នើសុំរបស់មេធាវីការពារឱ្យពិរុទ្ធជន

-ក្រោយពីបានស្តាប់សម្តីចុងក្រោយរបស់ពិរុទ្ធជន

-ក្រោយពីបានពិនិត្យលើឯកសារ ភស្តុតាងនានា

-ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់ហើយ ។

## សំអាងហេតុ

១- កាលពីថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១៨ ស្ថិតក្នុងភូមិសាស្ត្រក្រុងបានលុង ខេត្តរតនគិរី មិនមានការក្លែងបន្លំ និងប្រើប្រាស់ឯកសារសាធារណៈក្លែងដែលប្រព្រឹត្តដោយពិរុទ្ធជនឈ្មោះ [redacted] ត្លូង នោះទេ គឺជននេះបានប្រើប្រាស់សៀវភៅបន្ទុកភាសុី ស្តីពីការដាក់ទុនវិនិយោគ និងធ្វើអាជីវកម្មប្រមូលសម្អាត អនាម័យ និងដឹកជញ្ជូនសំរាមក្នុងក្រុងបានលុង ខេត្តរតនគិរី គឺពិតជាត្រឹមត្រូវតាមឯកសារដើមដែលក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានចេញឱ្យប្រើប្រាស់ និងតម្កល់ទុកនៅមន្ទីរដែលពាក់ព័ន្ធក្នុងខេត្តរតនគិរី ។

២-តុលាការបើកសវនាការលើបណ្តឹងទាស់លេខ ១៨៨ ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០២២ របស់ពិរុទ្ធជនឈ្មោះ [redacted] គួង ប្រឆាំងនឹងសាលក្រមលេខ ២២០ "ច" ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២២ របស់សាលាដំបូងខេត្តរតនគិរី គឺមានលក្ខណៈត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ ។

៣-ពិរុទ្ធជនឈ្មោះ [redacted] គួង នាពេលសវនាការបានឆ្លើយថា: នៅក្នុងខេត្តរតនគិរី មានការស្មុគស្មាញពាក់ព័ន្ធនឹងសំរាមដោយគ្មានអ្នកប្រមូលនោះទេ ប៉ុន្តែដោយខាងសាលាខេត្តត្រូវការអ្នកវិនិយោគ ខ្លួនក៏បានដាក់ពាក្យសុំចូលវិនិយោគតាមបែបបទរដ្ឋបាល ដោយវិនិយោគលើសំរាមនេះតែម្តង ហើយខាងអភិបាលខេត្តរតនគិរីបានចេញលិខិតលេខ ១៤១/០៩ ល.អ.ខ ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០០៩ ស្តីពីការប្រគល់សិទ្ធិអនុញ្ញាតឱ្យធ្វើអាជីវកម្មប្រមូលសំអាត និងដឹកជញ្ជូនសំរាមជាបណ្តោះអាសន្នរយៈពេល ០៣ខែ គឺចាប់ពីខែតុលា ដល់ខែធ្នូ ឆ្នាំ២០០៩ ដែលមានឈ្មោះខ្លួនជាម្ចាស់អាជីវកម្ម ។ ក្រោយពីអនុវត្តក្នុងអំឡុងពេល ០៣ខែ នោះ គឺឃើញមានប្រជាពលរដ្ឋខ្លះចូលរួមសហការ និងខ្លះទៀតមិនព្រមសហការក្នុងកាតព្វកិច្ចបង់ប្រាក់អនាម័យនោះទេ ហើយក្រោយមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានចេញលិខិតលេខ ៦៩២ ស.ហ.វ ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០១០ ហើយខាងក្រសួងបានឱ្យសាលាខេត្តរតនគិរី រៀបចំឯកសារជាកិច្ចសន្យា និងសៀវភៅបន្ទុកភាស៊ី ដោយយោងតាមលិខិតលេខ ៦៩២ ស.ហ.វ ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០១០ ។ ក្រោយពីឯកភាពលើកិច្ចសន្យាដែលបានរៀបចំសៀវភៅបន្ទុកភាស៊ី ស្តីពីការដាក់ទុនវិនិយោគធ្វើអាជីវកម្មប្រមូលភាស៊ីរយៈពេល ២១ឆ្នាំ ចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០១០ ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០៣០ ពេលនោះគឺខ្លួនឈប់ប្រើលិខិតបណ្តោះអាសន្ន ហើយខ្លួនបែរមកប្រើសៀវភៅបន្ទុកភាស៊ីដែលមានការចុះហត្ថលេខាពីមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងអភិបាលខេត្តរតនគិរី ចាប់តាំងពីអនុវត្តសៀវភៅបន្ទុកភាស៊ីនៅថ្ងៃទី០១ ខែមករា ឆ្នាំ២០១០ នោះមក គឺមានរយៈពេល ០៩ឆ្នាំមកហើយ ។

៤-សាក្សីឈ្មោះ [redacted] ខេមរៈ នាពេលសវនាការបានឆ្លើយនោះ មិនមានភាពច្បាស់លាស់នោះទេ ដែលតុលាការគប្បីមិនពិចារណាឡើយ ។

៥-នាពេលសវនាការឃើញថាពិរុទ្ធជនឈ្មោះ [redacted] គួង មិនបានប្រព្រឹត្តដូចការចោទប្រកាន់ពីមុនមកនោះឡើយ ។

៦-ផ្អែកតាមចម្លើយ និងភស្តុតាងដែលបានដាក់ជូនមកតុលាការឃើញថាពិរុទ្ធជនឈ្មោះ [redacted] គួង មិនបានប្រព្រឹត្ត និងពុំចូលធាតុផ្សំគ្រប់គ្រាន់ក្នុងបទល្មើស **ការក្លែងបន្លំ និងប្រើប្រាស់ឯកសារសាធារណៈក្លែង** ដែលមានបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា ៦២៦ មាត្រា ៦២៧ និងមាត្រា ៦៣០ នៃក្រមព្រហ្មទណ្ឌនោះឡើយ ។

៧-តាមសេចក្តីសន្និដ្ឋានស្នើសុំរបស់មេធាវីការពារសិទ្ធិឱ្យដើមបណ្តឹងគឺ សូមសំណូមពរឱ្យតុលាការ ធ្វើការសម្រេចតាមការទាមទារ និងសុំឱ្យផ្តន្ទាទោសជននោះទៅតាមផ្លូវច្បាប់ ហើយនិងសូមបញ្ជូលឯកសារពាក់ព័ន្ធមកតាមក្រោយ ។

៨-តាមសេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ ក្រោយពីបានពិភាក្សាដេញដោលចប់ ឃើញថាតំណាងអយ្យការប្តឹងសុំឱ្យដើមបណ្តឹងទាំងអស់ដាក់ឯកសារដើមលើភស្តុតាងនានាដែលពាក់ព័ន្ធក្នុងសំណុំរឿង តែមកដល់ពេលនេះមិនទាន់បានដាក់មកតុលាការនោះទេ ដូច្នេះតំណាងអយ្យការប្តឹងសុំឱ្យតុលាការពិចារណាឱ្យបានត្រឹមត្រូវតាមផ្លូវច្បាប់ គប្បីតុលាការពិចារណា ។

៩-តាមសេចក្តីសន្និដ្ឋានស្នើសុំរបស់មេធាវីការពារឱ្យពិរុទ្ធជន ឯកសារអ្វីដែលដើមបណ្តឹងប្តឹងកូនក្តីខ្លួន ដោយកូនក្តីមានសៀវភៅបន្ទុកភាស៊ីត្រឹមត្រូវ តែគាត់ថាកូនក្តីខ្លួនមានសៀវភៅនោះមិនត្រឹមត្រូវវិញ ចំណែកឯភស្តុតាងកូនក្តីខ្លួនបានដាក់បញ្ជូលមកតុលាការដើម្បីពិនិត្យគ្រប់គ្រាន់ ហើយដូច្នេះខ្លួនសូមសំណូមពរឱ្យតុលាការសម្រេចឱ្យកូនក្តីខ្លួនត្រូវបានរួចខ្លួនពីបទចោទដោយក្តីអនុគ្រោះ គប្បីតុលាការពិចារណា ។

១០-ពុំមានភស្តុតាង និងពិរុទ្ធភាពគ្រប់គ្រាន់ចោទប្រកាន់ទៅលើពិរុទ្ធជនឈ្មោះ [redacted] គួង ពីបទ: **ការក្លែងបន្លំ និងប្រើប្រាស់ឯកសារសាធារណៈក្លែង** ប្រព្រឹត្តនៅចំណុចភូមិសាស្ត្រក្រុងបានលុង ខេត្តរតនគិរី កាលពីថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១៨ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៦២៦ មាត្រា ៦២៧ មាត្រា ៦៣០ នៃក្រមព្រហ្មទណ្ឌនោះឡើយ ។



Scanned with CamScanner

## ហេតុដូច្នេះសម្រេច

១-កែប្រែសេចក្ដីសម្រេចនៃសាលក្រមព្រហ្មទណ្ឌលេខ ២២០ “ច” ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២២ របស់សាលាដំបូងខេត្តរតនគិរីទាំងស្រុង ។

២-ឱ្យពិរុទ្ធជនឈ្មោះ [redacted] គួង ភេទប្រុស អាយុ ៥៨ឆ្នាំ សញ្ជាតិខ្មែរ (មានអត្តសញ្ញាណខាងលើ) រួចខ្លួនពីបទចោទ ពីបទ៖ ការក្លែងបន្លំ និងប្រើប្រាស់ឯកសារសាធារណៈក្លែង ប្រព្រឹត្តនៅចំណុចភូមិសាស្ត្រក្រុងបានលុង ខេត្តរតនគិរី កាលពីថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១៨ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងឱ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា ៦២៦, មាត្រា ៦២៧ និងមាត្រា ៦៣០ និងមាត្រា ៣៥០ កថាខណ្ឌ៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

-សាលក្រមនេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី២៦ ខែតុលា ឆ្នាំ២០២២ ចំពោះមុខពិរុទ្ធជន[redacted] គួង និងកំបាំងមុខដើមបណ្ដឹងឈ្មោះ [redacted]ប៊ុនណា, ឈ្មោះ[redacted] គឹមហ៊ាន, ឈ្មោះ[redacted]ស៊ីដេត, ឈ្មោះ [redacted] សាយ និងប្រកាសជាសាធារណៈនៅថ្ងៃទី១៦ ខែមករា ឆ្នាំ២០២៣ ។

-ទុកសិទ្ធិឱ្យភាគីប្ដឹងឧទ្ធរណ៍ក្នុងរយៈពេលដែលច្បាប់បានកំណត់ ។

**ក្រឡាបញ្ជីសវនាការ**
ហត្ថលេខា និងត្រា
[redacted]

**ចៅក្រមជំនុំជម្រះ**
ហត្ថលេខា និងត្រា
[redacted]

............................................................................................................

បានឃើញ
**ចៅក្រមជំនុំជម្រះ**
[redacted]

“ បានចម្លងត្រឹមត្រូវតាមច្បាប់ដើម”
ថ្ងៃចន្ទ ១០ រោច ខែបុស្ស ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦
រតនគិរី, ថ្ងៃទី១៦ ខែមករា ឆ្នាំ២០២៣
**ក្រឡាបញ្ជី**
[redacted]

Scanned with CamScanner